# សេចក្តីប្រកាសព័ត៌មាន

## ការិយាល័យធនាគារពិភពលោកនៅកម្ពុជា

ទំនាក់ទំនង: នៅបាងកក: លោកស្រី ម៉ារៀ គ្រិស្ទីណា មេដ្យា
អ៊ីម៉ែល: cmejia@worldbank.org
នៅភ្នំពេញ: លោក ប៊ូ សារឿន
អ៊ីម៉ែល: sbou@worldbank.org

## ជប៉ុន និងធនាគារពិភពលោក គាំទ្រសហគមន៍ព្រៃឈើ និងការចូលរួមនៅក្នុងប្រទេសកម្ពុជា

**ភ្នំពេញ ថ្ងៃ ទី ១១ ខែ កញ្ញា ឆ្នាំ ២០០៦ :** ថ្ងៃនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារពិភពលោក និងមជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (RECOFTC) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជំនួយឥតសំណងរបស់មូលនិធិអភិវឌ្ឍន៍សង្គមជប៉ុន (JSDF) សំរាប់ការកសាងសមត្ថភាពផ្នែកគ្រប់គ្រងព្រៃឈើ និងដីប្រកបដោយចិរភាពនៅក្នុងខេត្តតាមជនបទចំនួន ៥ ក្នុងប្រទេសកម្ពុជា ។ ជំនួយឥតសំណងដែលមានទឹកប្រាក់ចំនួន ១,៧៦ លានដុល្លារនេះ ត្រូវបានផ្តល់អោយដោយរដ្ឋាភិបាលជប៉ុន តាមរយៈធនាគារពិភពលោក ហើយនឹងផ្តល់សំរាប់គំរោងថ្មីមួយ ក្នុងការជួយកសាងសមត្ថភាពដល់ភូមិនានាដែលអាស្រ័យនឹងព្រៃឈើ សំរាប់អោយពួកគាត់បង្កើតដៃគូថ្មី ជាមួយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល និងដើម្បីបង្កើតវិធីសាស្ត្រថ្មីសំរាប់គ្រប់គ្រងព្រៃឈើ និងការចូលរួមពិនិត្យតាមដានធនធានព្រៃឈើ និងដីធ្លី ។

ឯកឧត្តម តាកាហាស៊ិ ហ្វូមីអាគី ឯកអគ្គរាជទូតជប៉ុនប្រចាំប្រទេសកម្ពុជា មានប្រសាសន៍នៅឯពិធីចុះហត្ថលេខានេះ ថា *"គំរោងដែលគាំទ្រដោយមូលនិធិ អភិវឌ្ឍន៍សង្គមជប៉ុន នឹងចូលរួមចំណែកការពារព្រៃឈើ និងកែលំអការរស់នៅរបស់ប្រជាជនដែលអាស្រ័យលើព្រៃឈើ ។ ធនធានសហគមន៍នឹងត្រូវបានគ្រប់គ្រង និងការពារយ៉ាងត្រឹមត្រូវតាមរយៈសកម្មភាពនានាដែលអនុវត្តគំរោងនេះ ហើយប្រជាជននៅមូលដ្ឋាននឹងទទួលស្គាល់នូវសារៈសំខាន់នៃធនធានសហគមន៍របស់គេផ្ទាល់ ដោយរួមទាំងព្រៃឈើ ។ លើសពីនេះ គំរោងអាចរួមចំណែកយ៉ាងច្រើន មិនត្រឹមតែកសាងសមត្ថភាពនៅតាមសហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងជួយលើកកំពស់ប្រសិទ្ធិភាពនៃការប្រើប្រាស់ធនធានព្រៃឈើនៅក្នុងប្រទេសទាំងមូល ។"*

មូលនិធិអភិវឌ្ឍន៍សង្គមជប៉ុន (JSDF) ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលជប៉ុន និងធនាគារពិភពលោក នៅក្នុងខែ មិថុនា ឆ្នាំ ២០០០ ជាយន្តការរួមមួយសំរាប់ផ្តល់ជំនួយផ្ទាល់ដល់ជនក្រីក្រ និងក្រុមដែលងាយទទួលរងគ្រោះជាងគេបំផុត នៅក្នុងប្រទេសដែលជាសមាជិករបស់ធនាគារពិភពលោក និងដើម្បីកសាងសមត្ថភាពការចូលរួម និងផ្តល់អំណាចដល់សង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលនានា។ មកដល់ត្រឹមថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦ រដ្ឋាភិបាលជប៉ុន បានផ្តល់ប្រាក់ច្រើនជាង ២៥០ លានដុល្លារ ទៅអោយ JSDF និងជំនួយបច្ចេកទេស ជិត ២០០ ដែលមានទឹកប្រាក់សរុបច្រើនជាង ២៣៨

លានដុល្លារអាមេរិក ត្រូវបានអនុម័ត ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមមួយចំនួនធំ រួមមាន ផ្នែកនេសាទ អភិវឌ្ឍន៍ជីវភាពរស់នៅ អប់រំ សុខាភិបាល និងសេវាកម្មមូលដ្ឋានសំរាប់សហគមន៍ក្រីក្រ។

ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានប្រសាសន៍ថា *"ខ្ញុំសូមយកឱកាសនេះដើម្បីសំដែងនូវការអគុណចំពោះរដ្ឋាភិបាលជប៉ុន និងធនាគារពិភពលោក សំរាប់ការផ្តល់ជំនួយឥតសំណងនេះ ហើយជូនសមុខអោយរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមធានាថា វាជាការទទួលខុសត្រូវរបស់យើងក្នុងការប្រើប្រាស់ជំនួយឥតសំណងនេះអោយមានប្រសិទ្ធិភាព និងតម្លាភាព ដើម្បីសំរេចអោយបានតាមគោលបំណង ហើយខ្ញុំសង្ឃឹមថា RECOFTC ដែលជាភ្នាក់ងារអនុវត្តជំនួយនេះ នឹងអនុវត្តទៅតាមការតព្វកិច្ច ដែលបានចែងក្នុងកិច្ចព្រមព្រៀង ដើម្បីអនុវត្តគំរោងនេះអោយបានជោគជ័យសំរាប់ប្រជាជនកម្ពុជា ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការអនុវត្តដោយជោគជ័យនូវជំនួយបច្ចេកទេសនេះ នឹងផ្តល់អោយកម្ពុជានូវឱកាសច្រើនថែមទៀត ដើម្បីទាក់ទាញជំនួយបន្ថែមពីធនាគារពិភពលោក ក៏ដូចជាដៃគូអភិវឌ្ឍន៍ដទៃទៀតដែរ សំរាប់វិស័យនេះ ។"*

គំរោងដែលមានរយៈពេល ៤ ឆ្នាំ នេះ ផ្តោតទៅលើខេត្តសំខាន់ចំនួន ៥ គឺ ខេត្ត រតនគិរី កំពង់ធំ ក្រចេះ កំពត និងពោធិសាត់។ ការងារកសាងសមត្ថភាព ដែលគាំទ្រដោយជំនួយបច្ចេកទេសនេះ រួមមានដូចខាងក្រោម :

- **កម្មវិធីបណ្តុះបណ្តាលផ្នែកព្រៃឈើ សហគមន៍** ដោយបណ្តុះបណ្តាលអំពីក្របខណ្ឌច្បាប់ ព្រៃឈើសហគមន៍ និងការអនុវត្ត រួមទាំងការរៀបចំសហគមន៍ សំរបសំរួលការពិភាក្សា ធ្វើផែនទីសហគមន៍ និងកំណត់ព្រំដែន ធ្វើផែនការប្រើប្រាស់ដីដោយមានការចូលរួម បង្កើតផែនការគ្រប់គ្រងព្រៃ និងធ្វើកិច្ចព្រមព្រៀងព្រៃឈើសហគមន៍។
- **ការសាកល្បងភាពជាដៃគូនៃព្រៃឈើសហគមន៍** ផ្នែកនេះ គាំទ្រដល់ការរៀនសូត្រដកពិសោធន៍សំរាប់បុគ្គលិករដ្ឋាភិបាលដែលតែងតាំងថ្មី អង្គការមិនមែនរដ្ឋាភិបាល និងដៃគូរដ្ឋាភិបាលមូលដ្ឋានដែលនឹងចែករំលែកការទទួលខុសត្រូវសំរាប់អនុវត្តអនុក្រិត្យព្រៃឈើសហគមន៍ នៅថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ និង
- **ការពិនិត្យតាមដានដោយមានការចូលរួម ការវាយតំលៃ និងការផ្សព្វផ្សាយ** ការបង្កើតកម្មវិធីមួយដែលល្អ និងដែលមានការចូលរួម ដើម្បីជួយចែករំលែកការយល់ដឹងក្នុងចំណោមសហគមន៍ និងដៃគូអនុវត្ត គាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ដើម្បីអភិវឌ្ឍការគ្រប់គ្រងព្រៃឈើនិងដី និងប្រព័ន្ធតាមដាន និងគាំទ្រ ដល់អង្គភាពព្រៃឈើសហគមន៍របស់រដ្ឋបាលព្រៃឈើ ដើម្បីធ្វើការជាមួយបណ្តាញក្នុងមូលដ្ឋាន រួមមានការ វិភាគនិងការប្រមូលទិន្នន័យតាមទីកន្លែង ការទំនាក់ទំនង និងការផ្សព្វផ្សាយ។

លោក អៀន ផតផ័រ នាយកធនាគារពិភពលោកប្រចាំកម្ពុជា បានធ្វើការកត់សំគាល់ថា គំរោងនេះ "វាត្រូវគ្នាទាំងស្រុងជាមួយនឹងគោលបំណងមួយក្នុងការចូលរួមរបស់ធនាគារពិភពលោកនៅក្នុងប្រទេសកម្ពុជា ដើម្បីគាំទ្រដល់ការធ្វើកំណែទំរង់ស្ថាប័ន ដែលជួយជនក្រីក្រនៅតាមជនបទអោយនិយាយកាន់តែច្រើនឡើង និងទទួលបានអត្ថប្រយោជន៍កាន់តែច្រើន ពីការគ្រប់គ្រងធនធានធម្មជាតិដែលប្រកបដោយចិរភាព។"

លោក ផតធ័រ បានបន្ថែមទៀតថា *"ប្រសិនបើការអនុវត្តនេះទទួលបានជោគជ័យ គំរោងនេះ នឹងជួយពង្រឹងសមត្ថភាពរបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ដើម្បីគ្រប់គ្រងធនធានព្រៃឈើ ប្រកបដោយតម្លាភាព និងសមធម៌ និងមានប្រសិទ្ធិភាពខ្ពស់ ។"*

RECOFTC គឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយដែលមានមូលដ្ឋាននៅក្នុងទីក្រុងបាងកក។ អង្គការនេះ នឹងធ្វើការដោយសហការជាមួយរដ្ឋបាលព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរបស់កម្ពុជា ដើម្បីអនុវត្តគំរោងនេះ ក្នុងរយៈពេល៣ឆ្នាំ ខាងមុខបន្ទាប់ទៀត។ លោកបណ្ឌិត យ៉ាំ ម៉ាឡា នាយកប្រតិបត្តិរបស់ RECOFTC បានកត់សំគាល់ថា *"ប្រជាពលរដ្ឋនៅតាមជនបទ ត្រូវការធនធានព្រៃឈើ សំរាប់ទ្រទ្រង់និងកែលំអការរស់នៅរបស់ពួកគេ និងសំរាប់បំពេញសេចក្តីត្រូវការផ្សេងៗ ។ ព្រៃឈើសហគមន៍ តំណាងអោយឱកាសដ៏ធំមួយសំរាប់កាត់បន្ថយភាពក្រីក្រ និងវិសមធម៌សង្គម ។"*

សំរាប់ព័ត៌មានបន្ថែមស្តីអំពីសកម្មភាពរបស់ធនាគារពិភពលោកនៅក្នុងប្រទេសកម្ពុជា សូមអានវិបសាយរបស់យើង :

http://www.worldbank.org/kh